**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ [illegible]

*ថ្ងៃព្រហស្បតិ៍ ៩រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩*
*រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៦*

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដេញថ្លៃលក់មូលបត្ររដ្ឋលើកទី៤៣

យោងសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការដេញថ្លៃលក់មូលបត្ររដ្ឋលើកទី៤៣ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៦ ធនាគារជាតិនៃកម្ពុជាសូមជម្រាបជូនដំណឹងដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ ជ្រាបថា ការដេញថ្លៃលក់មូលបត្ររដ្ឋនឹងប្រព្រឹត្តទៅនៅថ្ងៃពុធ ១៥រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៦ តាមរយៈថ្នាល NBCP ចាប់ពីម៉ោង ៨:០០ព្រឹក ដល់ម៉ោង ២:៣០រសៀល និងមានព័ត៌មានលម្អិតដូចខាងក្រោម៖

| **គណប្រតិទាន (ឆ្នាំ)** | **២ ឆ្នាំ** | **៥ ឆ្នាំ** | **១០ ឆ្នាំ** | **២ ឆ្នាំ** | **៥ ឆ្នាំ** | **១០ ឆ្នាំ** |
|---|---|---|---|---|---|---|
| **រូបិយប័ណ្ណ** | ប្រាក់រៀល | | | ប្រាក់ដុល្លារអាមេរិក | | |
| លេខកូដស្តង់ដារ | KH300018DG32 | KH300018EG31 | KH300018FG30 | KH300018GG39 | KH300018HG38 | KH300018JG36 |
| អត្រាគូប៉ុង | ៣,២០% ថេរ | ៤,៤០% ថេរ | ៤,៨០% ថេរ | ២,៨០% ថេរ | ៣,៦០% ថេរ | ៤,៣០% ថេរ |
| តម្លៃចារឹក | ១.០០០.០០០ | | | ១.០០០ | | |
| ទំហំសរុប | មិនកំណត់ | | | | | |
| ថ្ងៃទូទាត់ | ២០-០៣-២០២៦ | | | | | |
| រយៈពេលទូទាត់គូប៉ុង | រៀងរាល់ ៦ខែម្តង | | | | | |
| ប្រភេទគណប្រតិទាន | ទូទាត់ប្រាក់ដើមសរុបចុងគ្រា | | | | | |
| វិធីសាស្ត្រដេញថ្លៃ | ពហុតម្លៃ | | | | | |
| ចំនួនស្នើដេញថ្លៃ | ច្រើនសំណើ | | | | | |
| បរិមាណអប្បបរមា | មិនកំណត់ | | | | | |
| បរិមាណអតិបរមា | មិនកំណត់ | | | | | |
| មូលដ្ឋានរាប់ថ្ងៃ | ជាក់ស្តែង/ជាក់ស្តែង | | | | | |

សេចក្តីដូចបានជម្រាបជូនខាងលើ សូមគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារមេត្តាជ្រាបជាព័ត៌មាន និងចូលរួមដេញថ្លៃតាមកាលបរិច្ឆេទខាងលើ តាមការគួរ។


សូមទំនាក់ទំនង : នាយកដ្ឋានសេវាធនាគារ នៃធនាគារជាតិនៃកម្ពុជា
លេខទូរស័ព្ទ : (៨៥៥-២៣) ៧២៤ ៩៦៣ ឬ (៨៥៥-២៣) ៧២២ ២២១ EXT. ១០៥៨
សារអេឡិចត្រូនិក : gs_info@nbc.gov.kh
បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា៖
www.nbc.gov.kh
ធនាគារជាតិ នៃកម្ពុជា - National Bank of Cambodia | National Bank of Cambodia
National Bank of Cambodia | nbccambodia
Natonal Bank of Cambodia | nationalbankofcambodia_